# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ....០៣៤.....ន. គ. ស/ស.ណ.ន.

ថ្ងៃអង្គារ ១០កើត ខែពិសាខ ឆ្នាំខាលចត្វាស័ក ព. ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០២២

## សេចក្ដីណែនាំ

## ស្ដីពី

## ការរាយការណ៍អំពីការបង្កកទ្រព្យសម្បត្តិដោយបុគ្គលរាយការណ៍ សម្រាប់វិស័យគណនេយ្យ និងសវនកម្ម

អនុលោមតាមច្បាប់ស្ដីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ បានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦២០/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ និយ័តករគណនេយ្យ និងសវនកម្ម (ន.គ.ស.) សូមធ្វើការណែនាំជូន ឧកញ៉ា លោក លោកស្រី កញ្ញាប្រធានក្រុមហ៊ុនគណនេយ្យ និងសវនកម្មទាំងអស់ជ្រាបថា ក្នុងករណីដែលក្រុមហ៊ុនគណនេយ្យ និងសវនកម្មដែលជាបុគ្គលរាយការណ៍ ឬបុគ្គលទទួលបន្ទុករាយការណ៍បានពិនិត្យឃើញមានសកម្មភាពការធ្វើហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ដូចមានចែងក្នុងច្បាប់នេះ និង/ឬច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ សូមរាយការណ៍អំពីទ្រព្យសម្បត្តិដែលបានបង្កកតាមអំណាចនៃសេចក្ដីសម្រេចរបស់តុលាការ និងរាល់ការប៉ុនប៉ងធ្វើប្រតិបត្តិការទៅលើទ្រព្យសម្បត្តិដែលបានបង្កកនោះ តាមមាត្រា១២ នៃច្បាប់ស្ដីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

ទន្ទឹមនឹងនេះ ចំពោះជនបង្គោលដែលជាតំណាងក្រុមហ៊ុនគណនេយ្យ និងសវនកម្ម ត្រូវរាយការណ៍តាមទម្រង់ដូចបានកំណត់នៅក្នុងឧបសម្ព័ន្ធដែលមានភ្ជាប់មកជាមួយសេចក្ដីណែនាំនេះ ឬអាចទាញយកទម្រង់បាននៅគេហទំព័រអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (https://www.nbc.org.kh/cafiu/laws_and_prakas.html) និងបញ្ជូនទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា តាមមាត្រា១២ នៃច្បាប់ស្ដីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

ទទួលបានសេចក្ដីណែនាំនេះ គ្រប់បុគ្គលរាយការណ៍ក្នុងវិស័យគណនេយ្យ និងសវនកម្មទាំងអស់ ត្រូវអនុវត្តតាមសេចក្ដីណែនាំនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**និយ័តករគណនេយ្យ និងសវនកម្ម**

**អគ្គនាយក**

**ប៊ូ ចារិន**

ចម្លងជូន៖

- អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីម៉ែល : info@acar.gov.kh
ទូរស័ព្ទ ០២៣ - ៨៨២ ១១១
Phone: 023 882 111

ឧបសម្ព័ន្ធ

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## ទម្រង់របាយការណ៍អំពីការបង្កកទ្រព្យសម្បត្តិដោយបុគ្គលរាយការណ៍
## Property Frozen Reporting Form for Reporting Entity

**យោង៖**

**With reference to:**

- ច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ឆ្នាំ២០២០
  Law on Combating the Financing of Proliferation of Weapons of Mass Destruction 2020
- អនុក្រឹត្យលេខ ១៦១ អនក្រ.បក ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីបែបបទ និងនីតិវិធីនៃការអនុវត្ត ច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
  Sub-Decree No. 161 ANK.BK dated 30 September 2020 on the Formalities and Procedures for the Implementation of the Law on Combating the Financing of Proliferation of Weapons of Mass Destruction
- អនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការប្រើប្រាស់និងការចាត់ចែងទ្រព្យសម្បត្តិបង្កកនៃហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
  Sub-Decree No. 159 ANK.BK dated 30 September 2020 on the Use and Management of Frozen Property from the Financing of Proliferation of Weapons of Mass Destruction
- ដីការសម្រេចបង្កកទ្រព្យសម្បត្តិលេខ១១ "ហ" ដ.ប.ទ និង លេខ១២ "ង១" ដ.ប.ទ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២០
  Standing Court Order on Property Freeze No.11 “H” DBT and No.12 “G1” DBT dated 02 November 2020

| I. អំពីបុគ្គលរាយការណ៍<br>**Reporting Entity** | |
|---|---|
| ក. នាមករណ៍របស់បុគ្គលរាយការណ៍<br>a. Name of Reporting Entity | |
| ខ. អាសយដ្ឋាន<br>b. Address | |
| គ. លេខសម្គាល់បុគ្គលរាយការណ៍<br>c. Reporting Entity ID | |
| ឃ. លេខទូរស័ព្ទ<br>d. Telephone Number | |
| ង. អាសយដ្ឋានអ៊ីមែល<br>e. Email Address | |
| ច. ផ្សេងៗ (ប្រសិនបើមាន)<br>f. Other (if any) | |

## II. អំពីទ្រព្យសម្បត្តិដែលបានបង្កកស្របតាមច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ

**Property Frozen as defined in the Law on Combating the Financing of Proliferation of Weapons of Mass Destruction**

| | |
|---|---|
| ក. ប្រភេទទ្រព្យសម្បត្តិ<br>a. Type of Property | |
| ខ. តម្លៃប៉ាន់ស្មាននៃទ្រព្យសម្បត្តិ<br>b. Estimated Value of Property | |
| គ. កាលបរិច្ឆេទនៃការបង្កក<br>c. Date of Freezing | |

[សូមពិពណ៌នាបន្ថែមអំពីទ្រព្យសម្បត្តិបង្កក ដែលត្រូវបានកាន់កាប់ដោយ បុគ្គលឬអង្គភាពជាម្ចាស់កម្មសិទ្ធិ ឬគ្រប់គ្រង បុគ្គលឬអង្គភាពតំណាង ឬស្ថិតក្រោមការដឹកនាំផ្ទាល់ ឬទ្រព្យសម្បត្តិបង្វែរមកពី ឬរកបានពីទ្រព្យសម្បត្តិបង្កក]

[Further description of the Property that is owned or controlled, of individual or entities acting on behalf of or the direction of and Property derived or generated from Frozen Property]

## III. អំពីជនសង្ស័យជាម្ចាស់ ឬបុគ្គលកំពុងគ្រប់គ្រងទ្រព្យសម្បត្តិដែលត្រូវបានបង្កក

**Suspected Owner(s) or Person (s) in control of the property Frozen**

| | |
|---|---|
| ក. ឈ្មោះ<br>a. Name | |
| ខ. ងារ<br>b. Title | |
| គ. ថ្ងៃ ខែ ឆ្នាំកំណើត<br>c. Date of Birth | |
| ឃ. សញ្ជាតិ<br>d. Nationality | |
| ង. មុខរបរ<br>e. Occupation | |
| ច. អាសយដ្ឋាន<br>f. Address | |
| ឆ. ឯកសារសម្គាល់អត្តសញ្ញាណ/លេខលិខិតឆ្លងដែន (ច្បាប់ចម្លងសំណៅដើម)<br>g. Identification Document/Passport Number (Copy Original) | |
| ជ. មូលហេតុនៃការបង្កកទ្រព្យសម្បត្តិ<br>h. Reason for Freezing the property | |
| ឈ. ព័ត៌មានលម្អិតផ្សេងទៀត (ប្រសិនបើមាន)<br>i. Other Detail (if any) | |

## IV. ប្រតិបត្តិការដែលប៉ុនប៉ងធ្វើទៅលើទ្រព្យសម្បត្តិដែលបានបង្កក (បន្ទាប់ពីទ្រព្យទ្រព្យសម្បត្តិត្រូវបានបង្កក) ប្រសិនបើមាន

**Attempted Transactions on Property Frozen (After Property Frozen), if any**

| | |
|---|---|
| **ក. បុគ្គលដែលបានប៉ុនប៉ងធ្វើប្រតិបត្តិការ**<br>**a. Person(s) who made attempted transaction** | |
| • ឈ្មោះ<br>• Name | |
| • ងារ<br>• Title | |
| • ថ្ងៃខែឆ្នាំកំណើត<br>• Date of Birth | |
| • សញ្ជាតិ<br>• Nationality | |
| • មុខរបរ<br>• Occupation | |
| • អាសយដ្ឋាន<br>• Address | |
| • ឯកសារសម្គាល់អត្តសញ្ញាណ/លេខលិខិតឆ្លងដែន (ច្បាប់ចម្លងសំណៅដើម)<br>Identification Document/Passport Number (Copy Original) | |
| • ប្រភពមូលនិធិ<br>• Source of Funds | |
| **ខ. បុគ្គលដែលពាក់ព័ន្ធនឹងប្រតិបត្តិការ**<br>**b. Person(s) who get involve with attempted transaction** | |
| • ឈ្មោះ<br>• Name | |
| • ងារ<br>• Title | |
| • ថ្ងៃ ខែ ឆ្នាំកំណើត<br>• Date of Birth | |
| • សញ្ជាតិ<br>• Nationality | |
| • មុខរបរ<br>• Occupation | |
| • អាសយដ្ឋាន<br>• Address | |

| | |
|---|---|
| • ឯកសារសម្គាល់អត្តសញ្ញាណ/លេខលិខិតឆ្លងដែន (ច្បាប់ចម្លងសំណៅដើម)<br>Identification Document/Passport Number (Copy Original) | |
| • ព័ត៌មានលម្អិតផ្សេងទៀត (ប្រសិនបើមាន)<br>• Other details (if any) | |
| **គ. អំពីប្រតិបត្តិការដែលប៉ុនប៉ងធ្វើ**<br>**a. Attempted Transaction Information** | |
| • គោលបំណង<br>• Purpose | |
| • ទីកន្លែង<br>• Location | |
| • តម្លៃប៉ាន់ស្មាន<br>• Estimated amount | |
| • កាលបរិច្ឆេទ<br>• Date | |
| • ព័ត៌មានលម្អិតផ្សេងទៀត (ប្រសិនបើមាន)<br>• Other details (if any) | |

| |
|---|
| **V. ព័ត៌មានបន្ថែម (ប្រសិនបើមាន)**<br>**Additional detailed information (if any)** |
| |

ថ្ងៃ..................ខែ........ឆ្នាំ..... ...ស័ក ព.ស. ២៥៦...

រាជធានីភ្នំពេញ ថ្ងៃទី........ ខែ........ ឆ្នាំ២០២...

Dated: DD/MM/YYYY

អគ្គនាយក

CEO

[ហត្ថលេខា]

[Signature and Stamp]